# ខួបលើកទី២០ នៃសេចក្តីប្រកាសរបស់ អ.ស.ប ស្តីពីអ្នកការពារសិទ្ធិមនុស្ស

## សេចក្តីថ្លែងការណ៍រួមដោយក្រុមប្រធាន អនុប្រធាន និងសមាជិកស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស អ.ស.ប និងអ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីអ្នកការពារសិទ្ធិមនុស្ស

សង្គមស៊ីវិលគឺជាសសរស្តម្ភដ៏សំខាន់មួយនៃប្រព័ន្ធសិទ្ធិមនុស្សអន្តរជាតិ។ សង្គមស៊ីវិលរួមចំណែកដល់ការលើកស្ទួយ និងគោរពសិទ្ធិមនុស្ស ការអភិវឌ្ឍន៍ប្រកបដោយចីរភាព ការរក្សាសន្តិភាព និងសន្តិសុខ ហើយនិងធ្វើសកម្មភាពស្របតាមគោលដៅនៃធម្មនុញ្ញអង្គការសហប្រជាជាតិ។

សង្គមស៊ីវិលធ្វើការវាយតម្លៃ និងរាយការណ៍អំពីថាតើរដ្ឋភាគីទាំងឡាយបំពេញ ឬមិនបំពេញកាតព្វកិច្ចសន្ធិសញ្ញារបស់ខ្លួន ដោយធ្វើការប្រែក្លាយបទប្បញ្ញត្តិនៃសន្ធិសញ្ញាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (សន្ធិសញ្ញា) ពាក់ព័ន្ធ ទៅជាសកម្មភាពនៅថ្នាក់មូលដ្ឋានដែរឬទេ។ ដូច្នេះ សង្គមស៊ីវិលដើរតួយ៉ាងសំខាន់ក្នុងការជួយដល់ស្ថានប័នសន្ធិសញ្ញាដើម្បីតាមឃ្លាំមើល និងការវាយតម្លៃការគោរពសន្ធិសញ្ញារបស់រដ្ឋភាគី។ ដោយសារតែតួនាទីដ៏សំខាន់នេះហើយ ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សស្នើឲ្យអង្គការសង្គមស៊ីវិលសហការជាមួយខ្លួន តាមរយៈការដាក់បញ្ជូនព័ត៌មានស្តីពីបញ្ហាពាក់ព័ន្ធនឹងការទទួលបាននូវសិទ្ធិនៅក្នុងប្រទេសដែលផ្តល់សច្ចាប័នលើសន្ធិសញ្ញាទាំងនោះ។

ការចូលរួម និងការបំពេញការងារយ៉ាងសកម្មរបស់សង្គមស៊ីវិលក្នុងការងាររបស់ស្ថាប័នសន្ធិសញ្ញា មានសារៈសំខាន់ណាស់សម្រាប់ការផ្សព្វផ្សាយដ៏ទូលំទូលាយនៅកម្រិតមូលដ្ឋាន កម្រិតជាតិ និងកម្រិតអន្តរជាតិ អំពីព័ត៌មានស្តីពីសន្ធិសញ្ញា និងការងាររបស់ស្ថាប័នសន្ធិសញ្ញា។ ក្នុងករណីជាច្រើន សេចក្តីសង្កេតចុងក្រោយ ឬទស្សនៈស្តីពីបណ្តឹងបុគ្គលដែលអនុម័តដោយស្ថានប័នសន្ធិសញ្ញា ទទួលបានការយកចិត្តទុកដាក់ និងទទួលយកទៅអនុវត្តកាន់តែច្រើន ដោយសារតែមានអន្តរាគមន៍ និងសកម្មភាពរបស់សង្គមស៊ីវិល។

ស្ថាប័នសន្ធិសញ្ញាបានលើកទឹកចិត្តដោយសង្កតភាពដល់រដ្ឋភាគីទាំងឡាយឲ្យទទួលស្គាល់ជាសាធារណៈ និងជាក់លាក់នូវតួនាទីរបស់សង្គមស៊ីវិល រួមទាំងអ្នកការពារសិទ្ធិមនុស្ស និងលើកទឹកចិត្តឲ្យពួកគេចូលរួមក្នុងដំណើរការពាក់ព័ន្ធទាំងអស់រាប់ទាំងការធ្វើរបាយការណ៍ផងដែរ។

អ្នករាយការណ៍ពិសេសស្តីពីអ្នកការពារសិទ្ធិមនុស្ស បានគូសបញ្ជាក់ពីរបៀបដែលស្ថាប័នសន្ធិសញ្ញាទទួលបានអត្ថប្រយោជន៍ពីព័ត៌មានដែលអ្នកការពារសិទ្ធិមនុស្សបានផ្តល់ដល់ស្ថាប័នទាំងនេះ។ ព័ត៌មាននេះ មានសារៈសំខាន់ណាស់ក្នុងការតាមឃ្លាំមើលការអនុវត្តសន្ធិសញ្ញា និងជាប្រព័ន្ធប្រកាសអាសន្នជាមុន ដើម្បីក្រើនរំលឹកដល់សហគមន៍អន្តរជាតិនូវការគំរាមកំហែងជាក់ស្តែងអាចកើតមាន ឬនឹងកើតមានពេលឆាប់ៗ ដល់សន្តិភាព សេរីភាព និងសន្តិសុខ។

នេះក៏ព្រោះតែអ្នកការពារសិទ្ធិមនុស្សខ្លួនឯងផ្ទាល់ផ្ទាល់គឺជាម្ចាស់សិទ្ធិ ហើយក៏ព្រោះតែពួកគេ ជួយដល់រដ្ឋភាគីក្នុងការធ្វើឲ្យសម្រេចបាននូវសិទ្ធិដែលមានចែងក្នុងសន្ធិសញ្ញា ហើយថាស្ថាប័នសន្ធិសញ្ញាលើកពីស្ថានភាពអ្នកការពារសិទ្ធិមនុស្សក្នុងកិច្ចសន្ទនារបស់ខ្លួន ជាមួយរដ្ឋភាគី ហើយនិយាយដោយចំៗអំពីពួកគេ នៅក្នុងសេចក្តីសង្កេតចុងក្រោយ សេចក្តីពន្យល់ទូទៅ ឬសេចក្តីថ្លែងការណ៍ជាសាធារណៈ។

អ្នកការពារសិទ្ធិមនុស្ស សំដៅដល់បុគ្គលណាមួយ ដែលជាឯកត្តបុគ្គល ឬដោយរួមជាមួយអ្នកដទៃ ធ្វើសកម្មភាព ឬព្យាយាមធ្វើសកម្មភាព ដើម្បីលើកស្ទួយ ការពារ ឬខិតខំប្រឹងប្រែងការពារ និងធ្វើឲ្យសម្រេចបាននូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន នៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងលើឆាកអន្តរជាតិ។ អ្នកការពារសិទ្ធិមនុស្សទាំងនោះធ្វើការតស៊ូមតិ លើកមូលហេតុបញ្ជាក់ថាត្រូវ ពង្រឹង ការពារ និងលើកស្ទួយនូវសិទ្ធិមនុស្ស។ អ្នកការពារសិទ្ធិមនុស្សមិនត្រឹមតែបង្ហាញឲ្យឃើញនូវការរំលោភសិទ្ធិមនុស្ស ដោយទាញការយកចិត្តទុករបស់អាជ្ញាធរលើផលវិបាកនៃសកម្មភាព និងការខកខានមិនបានបំពេញកាតព្វកិច្ចរបស់អាជ្ញាធរទាំងនោះ រាប់ទាំង សិទ្ធិដែលមានចែងក្នុងសន្ធិសញ្ញា ប៉ុណ្ណោះទេ ថែមទាំងជួយដល់រដ្ឋភាគីក្នុងការបង្កើតគោលនយោបាយសាធារណៈដែលអនុលោមតាមកាតព្វកិច្ចសន្ធិសញ្ញាទៀតផង។

ក្នុងការអនុវត្តសិទ្ធិរបស់ពួកគេ អ្នកការពារសិទ្ធិមនុស្ស ត្រូវស្ថិតក្រោមការដាក់កម្រិតព្រំដែនត្រឹមតែអ្វីដែលមានចែងដោយច្បាប់ អនុលោមតាម បទដ្ឋាន និងកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ ដោយសមហេតុផល ចាំបាច់ និងសមាមាត្រ ហើយសម្រាប់តែគោលបំណងមួយគត់ គឺដើម្បីធានាឲ្យមានការទទួលស្គាល់ និងការគោរពដោយត្រឹមត្រូវនូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់អ្នកដទៃ និងបំពេញតាមលក្ខខណ្ឌតម្រូវខាងសណ្តាប់ធ្នាប់សាធារណៈ និងសុខុមាលភាពទូទៅ នៅក្នុងសង្គមប្រជាធិបតេយ្យ។

សេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការសង្គម ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលត្រូវបានទទួលស្គាល់ជាសកល (សេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស) គូសបញ្ជាក់ជាថ្មី ដោយមានការពង្រឹងបន្ថែមដោយ និងបកស្រាយនូវការចងភ្ជាប់កាតព្វកិច្ចសិទ្ធិមនុស្ស រាប់ទាំង សិទ្ធិដែលមានចែងក្នុងសន្ធិសញ្ញា និងមានភាពពាក់ព័ន្ធទៅនឹងការបកស្រាយ និងការអនុវត្តសន្ធិសញ្ញា។

ស្ថាប័នសន្ធិសញ្ញាបានបញ្ជាក់ជាថ្មី អំពីសារៈសំខាន់នៃអ្នកការពារសិទ្ធិមនុស្ស ដែលអាចធ្វើសកម្មភាពដោយសេរី និងដោយមិនមានការជ្រៀតជ្រែក ការបំភិតបំភ័យ ការរំលោភបំពាន ការគំរាមកំហែង អំពើហឹង្សា ការសងសឹក ឬការរិតត្បិតហួសហេតុ។ ការបង្កើតបរិយាកាសអំណោយផល និងមានសុវត្ថិភាព រាប់ទាំង តាមរយៈការលើកស្ទួយការគោរព និងការគាំទ្រដល់សកម្មភាពនានារបស់អ្នកការពារសិទ្ធិមនុស្ស មានសារៈសំខាន់សម្រាប់ការលើកស្ទួយ ការគាំពារ និងការពារសិទ្ធិមនុស្ស។ ស្ថាប័នសន្ធិសញ្ញាចាត់ទុកការជ្រៀតជ្រែក បំភិតបំភ័យ ការរំលោភបំពាន ការគំរាមកំហែង អំពើហឹង្សា ការសងសឹក ឬការរិតត្បិតហួសហេតុ ប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស ថាជាការរួមចំណែកឲ្យមានការរំលោភលើកាតព្វកិច្ចរបស់រដ្ឋ ក្នុងការឈានទៅសម្រេចបាននូវសិទ្ធិដែលមានចែងនៅក្នុងសន្ធិសញ្ញា។

ដោយគិតទៅកាតព្វកិច្ចរបស់រដ្ឋភាគី ក្នុងការគោរព ការពារ និងអនុវត្តសិទ្ធិដែលមានចែងនៅក្នុងសន្ធិសញ្ញា អង្គការសន្ធិសញ្ញាសូមរំលឹករដ្ឋភាគី អំពីទំនួលខុសត្រូវរបស់ខ្លួន ក្នុងការធានាថា អ្នកការពារសិទ្ធិមនុស្ស ត្រូវបានការពារយ៉ាងមានប្រសិទ្ធិភាពពីការជ្រៀតជ្រែករំខាន ការបំភិតបំភ័យ ការរំលោភបំពាន ការគំរាមកំហែង អំពើហិង្សា ការសងសឹក ឬការរិតត្បិតហួសហេតុ

ណាមួយ និងផលវិបាកអវិជ្ជមានណាមួយផ្សេងទៀត ដែលពួកគេអាចជួបប្រទះ ពាក់ព័ន្ធនឹងសកម្មភាពរបស់ពួកគេក្នុងការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិ រាប់បញ្ចូលទាំង តាមរយៈកិច្ចសហការ និងការចូលរួមជាមួយស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សផងដែរ។ ដូចបានកត់សម្គាល់ក្នុងគោលការណ៍ណែនាំប្រឆាំងនឹងការបំភិតបំភ័យ ឬការសងសឹក ("គោលការណ៍ណែនាំសង់ចូសេ"1) ស្ថាប័នសន្ធិសញ្ញាសូមថ្កោលទោសយ៉ាងខ្លាំងចំពោះសកម្មភាពបំភិតបំភ័យ ឬការសងសឹក រាប់ទាំងការប្រឆាំងនឹងអ្នកដែលស្វែងរកកិច្ចសហការ សហការ ឬអ្នកដែលបានសហការ ជាមួយស្ថាប័នសន្ធិសញ្ញា។

តាមរយៈការធ្វើជាភាគីនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ រដ្ឋមួយត្រូវសន្យាសហការជាមួយស្ថាប័នសន្ធិសញ្ញាដោយសុទ្ធចិត្ត។ ដូចដែលបានកត់សម្គាល់នៅក្នុងគោលការណ៍ណែនាំសង់ចូសេ រដ្ឋទាំងឡាយមានភារកិច្ចការពារបុគ្គល និងក្រុមទាំងឡាយ ហើយត្រូវយកចិត្តទុកបំពេញភារកិច្ចនោះដោយប្រុងប្រយ័ត្ន។ ការបំភិតបំភ័យ ឬការសងសឹក អាចជាលទ្ធផលនៃទង្វើ ឬការខកខានមិនបានបំពេញកាតព្វកិច្ច ដោយតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ។ អំពើ ឬការខកខានមិនបានបំពេញកាតព្វកិច្ច ប៉ះពាល់ដល់រដ្ឋ នៅពេលអំពើ ឬការខកខានមិនបានបំពេញកាតព្វកិច្ចទាំងនោះត្រូវបានអនុវត្តដោយមានការយល់ព្រម ឬទទួលស្គាល់ពីមន្ត្រី ឬបុគ្គលផ្សេងទៀត ដែលបំពេញការងារក្នុងនាមជាមន្ត្រីមួយរូប ប្រឆាំងនឹងបុគ្គល ឬក្រុមណាមួយដែលកំពុងស្វែងរកកិច្ចសហការ ដែលកំពុងសហការ ឬដែលបានសហការជាមួយស្ថានប័នសន្ធិសញ្ញាណាមួយនោះ។

ស្ថាប័នសន្ធិសញ្ញាចាត់ទុកថា ការនិយាយយោងទៅលើ "ទស្សនៈនយោបាយ ឬមតិផ្សេង" និង "ស្ថានភាពដទៃផ្សេងទៀត" នៅក្នុងបរិបទនៃការរើសអើង ដែលត្រូវបានហាមឃាត់ដោយសន្ធិសញ្ញា គឺរាប់ទាំង ឋានៈរបស់បុគ្គលជាអ្នកការពារសិទ្ធិមនុស្ស។ ម្យ៉ាងវិញទៀត សិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងការការពារស្មើគ្នាពីច្បាប់ ហាមប្រាមការរើសអើងក្នុងការអនុវត្តសិទ្ធិ រាប់ទាំងសិទ្ធិទាំងឡាយដែលមានចែងនៅក្នុងសន្ធិសញ្ញា និងសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស។

រដ្ឋទាំងឡាយគួរចាត់វិធានការជាក់លាក់ ដើម្បីធានាការពារ និងគាំទ្រអ្នកការពារសិទ្ធិមនុស្ស ស្របតាមសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស និងអនុសាសន៍របស់អ្នករាយការណ៍ពិសេស។ ជាពិសេសរដ្ឋគួរតែ៖

១. ទទួលស្គាល់ជាសាធារណៈអំពីសារៈសំខាន់ និងភាពស្របច្បាប់នៃការងាររបស់អ្នកការពារសិទ្ធិមនុស្ស និងអះអាងជាថ្មីថាមិនមានការជ្រៀតជ្រែក ការបំភិតបំភ័យ ការរំលោភបំពាន ការគំរាមកំហែង អំពើហិង្សា ឬការសងសឹកទៅលើពួកគេនឹងត្រូវបានអត់ឱនឡើយ;

២. អនុម័តច្បាប់ និងគោលនយោបាយដែលធានាការពារជាក់លាក់ចំពោះអ្នកការពារសិទ្ធិមនុស្ស ដោយផ្តោតជាពិសេសចំពោះស្ថានភាព និងតម្រូវការការពាររបស់ក្រុមអ្នកការពារសិទ្ធិមនុស្សក្នុងស្ថានភាពងាយរងគ្រោះ ដូចជា អ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងអ្នកការពារសិទ្ធិជាកុមារ។

៣. អនុម័តវិធានការទាន់ពេលវេលា ដើម្បីបង្ការការជ្រៀតជ្រែក ការបំភិតបំភ័យ ការរំលោភបំពាន ការគំរាមកំហែង អំពើហិង្សា វាយប្រហារ ឬការសងសឹក ទៅលើអ្នកការពារសិទ្ធិមនុស្ស រួមមាន តាមរយៈការបង្កើតយន្តការពិសេសមួយសម្រាប់ការពារអ្នកការពារសិទ្ធិមនុស្ស

៤. ធ្វើការស៊ើបអង្កេតឲ្យបានឆាប់រហ័ស ម៉ត់ចត់ និងមិនលំអៀង ទៅលើការជ្រៀតជ្រែក បំភិតបំភ័យ ការរំលោភបំពាន ការគំរាមកំហែង អំពើហឹង្សា ឬការសងសឹក ទៅលើអ្នកការពារសិទ្ធិមនុស្ស និងធានាឲ្យមានគណនេយ្យភាពសម្រាប់ចារី។

៥- ធ្វើវិសោធនកម្ម ឬលុបចោលច្បាប់ណាមួយ ដែលដាក់ទោសទណ្ឌ ឬរារាំងដល់ការងាររបស់អ្នកការពារសិទ្ធិមនុស្ស រាប់ទាំង ការរឹតត្បិតមិនច្បាស់លាស់ និងមានលក្ខណៈទូលំទូលាយខ្លាំង លើសេរីភាពជាមូលដ្ឋាន (រួមមានសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពខាងសមាគម និងសិទ្ធិក្នុងការជួបជុំដោយសន្តិវិធី) ក៏ដូចជា បទបញ្ញត្តិដែលហាមប្រាម ដាក់កម្រិតព្រំដែន ឬរារាំងពួកគេ មិនឲ្យគៀរគរ ទទួល និងប្រើប្រាស់ធនធាននានា រាប់ទាំង ប្រភពបានមកពីក្នុងស្រុក និងបានមកពីក្រៅស្រុក។

៦. ពង្រឹងស្ថាប័នរដ្ឋដែលទទួលខុសត្រូវក្នុងការធានាការពារ និងការគាំទ្រកិច្ចការរបស់អ្នកការពារសិទ្ធិមនុស្ស។

កំណត់សំគាល់៖

១. គោលការណ៍ណែនាំប្រឆាំងនឹងការបំភិតបំភ័យ ឬការសងសឹក ("គោលការណ៍ណែនាំសង់ចូសេ"), 2015, HRI/MC/2015/6